Khmer

# សុវត្ថិភាពតាមផ្លូវថ្នល់



## ការរក្សាសុវត្ថិភាពកូនរបស់អ្នក នៅពេលអ្នកដឹកកូនដាក់នៅសាលា និងយកកូនពីសាលា

ទាំងនេះគឺជាប្រការមួយចំនួនដែលអ្នកអាចធ្វើបាន ដើម្បីជួយរក្សាសុវត្ថិភាពកូនរបស់អ្នក និងអ្នកដទៃទៀតក្នុងអំឡុងពេលដឹកកូនដាក់សាលា និងយកកូនពីសាលាក្នុងអំឡុងសប្តាហ៍រៀន៖

- ធានាថាកូនរបស់អ្នកបានពាក់ខ្សែក្រវាត់សុវត្ថិភាពនៅកៅអីកូនក្មេងក្នុងរថយន្តឱ្យបានត្រឹមត្រូវ ហើយធានាថាបានពាក់ត្រឹមត្រូវ។
- ប្រកាន់ភ្ជាប់ល្បឿនកំណត់៤០គីឡូម៉ែត្រ/ម៉ោងនៅក្នុងតំបន់សាលារៀន ហើយរំពៃមើលក្រែងមានកុមារបម្រុងដើរឆ្លងផ្លូវ។
- មើលភ្លើងភ្លឹបភ្លែតៗជាសញ្ញានៅលើរថយន្តក្រុង។ ភ្លើងសញ្ញាទាំងនេះអនុញ្ញាតឱ្យអ្នកដឹងថាអាចមានកូនក្មេងដើរឆ្លងផ្លូវ ឬបម្រុងនឹងដើរឆ្លងផ្លូវ។ ល្បឿនកំណត់៤០គីឡូម៉ែត្រ/ម៉ោងត្រូវបានអនុវត្តនៅពេលរថយន្តក្រុងបើកភ្លើងសញ្ញាភ្លឹបភ្លែតៗ។
- ត្រូវបើកផ្លូវឱ្យអ្នកថ្មើរជើង ជាពិសេសនៅពេលបើកចូល និងបើកចេញពីច្រកផ្លូវឡាន។
- ត្រូវចតឡាន និងបត់ឡានឱ្យបានត្រឹមត្រូវតាមច្បាប់ចរាចរណ៍នៅជុំវិញសាលារៀន។ ការបត់ឡានទៅក្រោយរាងជាអក្សរ U (U-turns) និងការបត់ឡានទៅក្រោយតាមរបៀប three-point turns គឺមានគ្រោះថ្នាក់ក្នុងអំឡុងពេលមមាញឹក ក្នុងការដឹកកូនដាក់នៅសាលា និងយកកូនពីសាលា។
- ដឹកកូនរបស់អ្នកដាក់នៅសាលា និងយកកូនរបស់អ្នកពីសាលា នៅពីចំហៀងផ្លូវសាលា នៅក្នុងបរិវេណតំបន់ដែលកំណត់សម្រាប់ដឹកកូនដាក់នៅសាលា និងយកកូនពីសាលា។ មិនត្រូវស្រែកហៅកូនពីម្ខាងផ្លូវថ្នល់ឡើយ – ពួកគេអាចរត់ទៅរកអ្នក ដោយមិនបានឆែកមើលចរាចរណ៍។
- វាមានសុវត្ថិភាពបំផុត ដែលកុមារត្រូវចេញពីរថយន្តតាមទ្វារសុវត្ថិភាពនៅពីទ្វារម្ខាងទៀត ឆ្ងាយពីចរាចរណ៍កំពុងបើកបរ។ នេះគឺជាទ្វាររថយន្តខាងក្រោយនៅចំហៀងផ្លូវដើរ។

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅគេហទំព័រ
**safetytown.com.au**

NSW GOVERNMENT

ជីវិតមនុស្សដែលបានបាត់បង់នៅលើផ្លូវថ្នល់រដ្ឋ NSW។
**គោលដៅរបស់យើង  គឺគ្មានគ្រោះថ្នាក់ ។**

TOWARDS ZERO

# ការដើរទៅសាលា និងមកពីសាលា ជាមួយគ្នាដោយសុវត្ថិភាព

ការដើរទៅសាលា និងដើរមកផ្ទះវិញ គឺជាវិធីដ៏ល្អមួយដើម្បីចំណាយពេលជាមួយកូនៗរបស់អ្នក ហើយលើកទឹកចិត្តឱ្យប្រកាន់អាកប្បកិរិយាដែលមានសុវត្ថិភាព និងសុខភាពល្អ។

ទាំងនេះគឺជាប្រការមួយចំនួនដែលអ្នកអាចធ្វើបាន ដើម្បីជួយរក្សាសុវត្ថិភាពកូនរបស់អ្នក ជាអ្នកថ្មើរជើង៖

- និយាយជាមួយកូនរបស់អ្នក អំពីការប្រុងប្រយ័ត្នក្នុងបរិវេណផ្លូវថ្នល់។
- រៀបចំគម្រោង និងអនុវត្តការធ្វើដំណើរទៅសាលា ដូច្នេះអ្នកអាចប្រើប្រាស់កន្លែងអ្នកថ្មើរជើងដើរឆ្លងកាត់ ពេលណាដែលអាចធ្វើបាន។
- កាន់ដៃកូនរបស់អ្នកជានិច្ច។ កូនក្មេងត្រូវការជំនួយរបស់អ្នកដើម្បីរកមើលឧបសគ្គគ្រោះថ្នាក់ ដូចជារថយន្តកំពុងបើកចេញពីច្រកផ្លូវឡាន។ កុមារក៏អាចធ្វើឱ្យបង្វែរអារម្មណ៍យ៉ាងងាយដែរ ហើយវង្វេងចូលទៅក្នុងផ្លូវចរាចរណ៍។
- ទៅយកកូនរបស់អ្នកនៅជិតក្លោងទ្វារសាលា ហើយមិនត្រូវស្រែកហៅកូនពីម្ខាងផ្លូវថ្នល់ឡើយ។
- ពន្យល់ពីមូលហេតុដែលអ្នកបានជ្រើសរើសកន្លែងនេះ ថាជាកន្លែងសុវត្ថិភាពបំផុតដើម្បីដើរឆ្លងផ្លូវ។
- រំលឹកកូនរបស់អ្នកឱ្យ**ឈប់! មើល! ស្តាប់! គិត!** រាល់ពេលដែលពួកគេដើរឆ្លងផ្លូវ ហើយបន្តឆែកមើលផ្លូវរហូតទាល់តែបានដើរឆ្លងផុតដោយសុវត្ថិភាព។
- និយាយទៅកាន់ពួកគេអំពីមូលហេតុដែលពួកគេគួរតែឈប់ មើល ស្តាប់ និងគិត មុនពេលដើរឆ្លងច្រកផ្លូវឡានផ្លូវថ្នល់ ឬកន្លែងចតរថយន្ត។

កុមារតូចៗអាចរៀន និងអនុវត្តអាកប្បកិរិយាអ្នកថ្មើរជើងដែលមានសុវត្ថិភាពជាមួយអ្នក។ ការនេះនឹងជួយឱ្យពួកគេក្លាយជាអ្នកថ្មើរជើងដែលមានសុវត្ថិភាពជាងមុន នៅពេលពួកគេមានអាយុល្មមគ្រប់គ្រាន់ក្នុងការធ្វើដំណើរតែម្នាក់ឯង។

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅគេហទំព័រ
**safetytown.com.au**



### សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នក ដែលរៀននៅមត្តេយ្យសាលា ទៅថ្នាក់ទី២

- កាន់ដៃរបស់ក្មេងជំពេលណា៖
  - អ្នកដើរឆ្លងផ្លូវ
  - អ្នកស្ថិតនៅលើផ្លូវដើរ
  - អ្នកស្ថិតនៅកន្លែងចតរថយន្ត

### សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នក ដែលរៀននៅថ្នាក់ទី៣ ទៅថ្នាក់ទី៦

- ប្រើកន្លែងសុវត្ថិភាពដើម្បីដើរឆ្លងផ្លូវ
- **ឈប់! មើល! ស្តាប់! គិត!** រាល់ពេលអ្នកដើរឆ្លងផ្លូវ ហើយបន្តឆែកមើលផ្លូវ រហូតទាល់តែបានដើរឆ្លងផុតដោយសុវត្ថិភាព

**ឈប់! (STOP!)**
ថយមួយជំហានពីចិញ្ចើមផ្លូវ

**មើល! (LOOK!)**
ផ្លូវទាំងសងខាងជាបន្តតឥតឈប់

**ស្តាប់! (LISTEN!)**
រកសំឡេងចរាចរណ៍ដែលបើកជិតមកដល់

**គិត! (THINK!)**
ថាតើវាមានសុវត្ថិភាពក្នុងការដើរឆ្លងផ្លូវឬទេ ហើយបន្តឆែកមើលផ្លូវ រហូតទាល់តែបានដើរឆ្លងផុតដោយសុវត្ថិភាព

# ការរក្សាសុវត្ថិភាពកុមារក្នុងរថយន្ត និងចេញពីរថយន្ត

កុមារដែលបានពាក់ខ្សែក្រវាត់ត្រឹមត្រូវ នៅក្នុងកៅអីសុវត្ថិភាពកុមារក្នុងរថយន្តដែលបានអនុញ្ញាត ទំនងជាមានគ្រោះថ្នាក់ដល់ជីវិត ឬរងរបួសតិចនៅក្នុងគ្រោះថ្នាក់បុកគ្នា ជាងកុមារដែលមិនបានពាក់ខ្សែក្រវាត់។

កុមារដែលមានអាយុចន្លោះពីបួន ទៅប្រាំពីរឆ្នាំមិនអាចធ្វើដំណើរអង្គុយនៅកៅអីខាងមុខនៃរថយន្តដែលមានពីរជួរ ឬច្រើនជួរបានទេលើកលែងតែកៅអីខាងក្រោយផ្សេងទៀតទាំងអស់ ត្រូវបានអង្គុយដោយកុមារអាយុក្រោមប្រាំពីរឆ្នាំ នៅក្នុងកៅអីសុវត្ថិភាពកុមារក្នុងរថយន្ត។

ច្បាប់ជាតិស្តីពីកៅអីសុវត្ថិភាពកុមារក្នុងរថយន្ត តម្រូវឱ្យកូនរបស់អ្នកអង្គុយនៅក្នុងកៅអីសុវត្ថិភាពកុមារក្នុងរថយន្ត ដូចខាងក្រោម៖

**0 – ៦ខែ**
កៅអីកុមារបែរមុខទៅក្រោយ ដែលបានអនុញ្ញាតដោយច្បាប់។

**៦ខែ – ៤ឆ្នាំ**
កៅអីកុមារបែរមុខទៅក្រោយ ឬបែរទៅមុខ ដែលបានអនុញ្ញាតដោយច្បាប់។

**៤+ ឆ្នាំ**
កៅអីកុមារបែរទៅមុខ ឬកៅអីបន្ទុប ដែលបានអនុញ្ញាតដោយច្បាប់។

**កម្ពស់១៤៥សង់ទីម៉ែត្រ ឬខ្ពស់ជាងនេះ**
កម្ពស់អប្បបរមាដែលគួរប្រើខ្សែក្រវាត់ភ្លៅ-ឆៀងរបស់មនុស្សធំ។

ចំពោះព័ត៌មានបន្ថែម និងដើម្បីស្វែងរក និងប្រៀបធៀបកៅអីកុមារក្នុងរថយន្តជាច្រើនប្រភេទ សូមចូលទៅកាន់វិបសៃ **childcarseats.com.au**

ទាំងនេះគឺជាប្រការមួយចំនួនដែលអ្នកអាចធ្វើបាន ដើម្បីជួយរក្សាសុវត្ថិភាពកូនរបស់នៅក្នុងរថយន្ត និងចេញពីរថយន្ត៖

- កុមារគួរតែរក្សាអង្គុយក្នុងរថយន្ត រហូតដល់មនុស្សធំបើក 'ទ្វារសុវត្ថិភាព'។ នេះគឺជាទ្វាររថយន្តខាងក្រោយនៅចំហៀងផ្លូវដើរ។
- កុមារដែលកំពុងគេង ត្រូវរក្សាពាក់ខ្សែក្រវាត់ឱ្យជាប់ខណៈកំពុងជិះក្នុងរថយន្ត។
- ជួយកូនរបស់អ្នកពាក់ខ្សែក្រវាត់សុវត្ថិភាព - ហើយមិនមួលត្របាញ់ចូលគ្នា។
- ត្រូវដាក់កំណត់ថា គ្រប់អ្នកដំណើរត្រូវពាក់ខ្សែក្រវាត់ឱ្យជាប់ ឬពាក់ខ្សែក្រវាត់នៅក្នុងកៅអីកុមារ មុនពេលអ្នកចាប់ផ្តើមបញ្ឆេះរថយន្ត។
- ជួយកូនរបស់អ្នកចូលក្នុងរថយន្ត និងចេញពីរថយន្តតាម 'ទ្វារសុវត្ថិភាព' ជានិច្ច។

មិនត្រូវទុកកុមារក្នុងវ័យណាមួយចោលក្នុងរថយន្ត ដោយគ្មានការមើលខុសត្រូវពីមនុស្សធំឡើយ។ កុមារអាចទទួលរងការឈឺចាប់យ៉ាងឆាប់រហ័សដោយសារកង្វះជាតិទឹកក្នុងខ្លួន អស់កម្លាំងដោយសារកម្តៅថ្ងៃ និងសរីរាង្គមិនដំណើរការ ប្រសិនបើត្រូវបានទុកចោលដោយមិនបានមើល ជាពិសេសនៅថ្ងៃក្តៅ។

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅត្រង់វិបសៃ **safetytown.com.au**



### សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នក

- ចុចពាក់ខ្សែក្រវាត់ខាងមុខ និងខាងក្រោយ (Click, clack, front and back)
- សូមពាក់ខ្សែក្រវាត់សុវត្ថិភាពអោយជាប់ជានិច្ច
- ចូល និងចេញពីរថយន្តពីចំហៀងផ្លូវដើរ

# សុវត្ថិភាពតាមផ្លូវថ្នល់

## កាន់ដៃកូនរបស់អ្នក

ជាអ្នកថ្មើរជើង កុមារអាចធ្វើឱ្យបង្វែរអារម្មណ៍យ៉ាងងាយ ហើយជាញឹកញយមានរាងតូចពេករហូតដល់អ្នកបើកបរឃើញមិនឃើញ។ ពួកគេប្រហែលជាមិនអាចព្យាករណ៍ ឬកំណត់ពីគ្រោះថ្នាក់ ហើយលំអៀងទៅនឹងការប្រព្រឹត្តដោយមិនបានគិត។

និយាយជាមួយកូនរបស់អ្នកអំពីឥរិយាបថសុវត្ថិភាពនៅលើផ្លូវដើរ – វាមិនមែនជាកន្លែងលេងដែលមានសុវត្ថិភាពទេ ដោយសារវានៅជិតផ្លូវ ហើយរថយន្តអាចបើកចូល ឬបើកចេញពីច្រកផ្លូវឡាន។

ត្រូវកាន់ដៃកូនរបស់អ្នក រហូតទាល់តែកូនរបស់អ្នកមានអាយុយ៉ាងហោចណាស់ប្រាំបីឆ្នាំ៖

- នៅលើផ្លូវដើរ
- នៅកន្លែងចតរថយន្ត
- នៅពេលដើរឆ្លងផ្លូវ។

ត្រូវមើលខុសត្រូវកូនរបស់អ្នកឱ្យបានជិតដល់ រហូតទាល់តែកូនរបស់អ្នកមានអាយុយ៉ាងហោចណាស់១០ឆ្នាំ ដោយកាន់ដៃវានៅពេលដើរឆ្លងផ្លូវ។

ប្រសិនបើអ្នកមិនអាចនៅជាមួយកូនរបស់អ្នកបានទេ ត្រូវរៀបចំមនុស្សធំម្នាក់ទៀតដែលអាចទុកចិត្តបាន ដើម្បីអមដំណើរពួកគេ។

ក្រោយចេញពីសាលា ត្រូវទៅយកកូនរបស់អ្នកនៅក្លោងទ្វារសាលា។ នៅម៉ោងចេញពីសាលា កុមារអាចមានចិត្តរំភើប បែកអារម្មណ៍ ឬអស់កម្លាំង ហើយជារឿយៗ មិនផ្តោតអារម្មណ៍លើសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេទេ។

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅគេហទំព័រ **safetytown.com.au**




### សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នក ដែលរៀននៅមត្តេយ្យសាលា ទៅថ្នាក់ទី២

- កាន់ដៃរបស់ក្មេងធំពេលណា៖
  - អ្នកដើរឆ្លងផ្លូវ
  - អ្នកស្ថិតនៅលើផ្លូវដើរ
  - អ្នកស្ថិតនៅកន្លែងចតរថយន្ត
- កាន់ដៃមនុស្សធំពេលណាអ្នកដើរឆ្លងផ្លូវ

### សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នក ដែលរៀននៅថ្នាក់ទី៣ ទៅថ្នាក់ទី៦

- ប្រើកន្លែងសុវត្ថិភាពដើម្បីដើរឆ្លងផ្លូវ
- **ឈប់! មើល! ស្តាប់! គិត! (Stop! Look! Listen! Think!)** រាល់ពេលអ្នកដើរឆ្លងផ្លូវ ហើយបន្តឆែកមើលផ្លូវ រហូតទាល់តែបានដើរឆ្លងផុតដោយសុវត្ថិភាព

Khmer

# សុវត្ថិភាពតាមផ្លូវថ្នល់



## ការពាក់មួកសុវត្ថិភាព និងការជិះកង់ដោយសុវត្ថិភាព

### ការពាក់មួកសុវត្ថិភាព

កូនរបស់អ្នកត្រូវពាក់មួកសុវត្ថិភាព នៅពេលជិះកង់នៅទីកន្លែងសាធារណៈណាមួយ – នេះគឺជាច្បាប់។ មួកសុវត្ថិភាពត្រូវតែបំពេញតាមស្តង់ដារនៃប្រទេសអូស្ត្រាលី និងញូវហ្សេឡង់ ហើយត្រូវពាក់ឱ្យជាប់ និងសមត្រូវក្បាលរបស់កូនអ្នក។ មួកសុវត្ថិភាពគួរតែពាក់ដោយដាក់គន្លឹះឱ្យជាប់ដើម្បីឱ្យត្រូវល្មម ដោយគ្មានការរង្កើរ ឬរអិលទៅម្ខាង។

ត្រូវចងចាំពិនិត្យមើលជានិច្ចថា កូនរបស់អ្នកពាក់មួកសុវត្ថិភាពនៅពេលណាវាកំពុងលេង ឬជិះវត្ថុដែលមានកង់ –

- កង់ជិះ
- កង់ក្មេងជិះរុញ ហើយឈរពីលើ
- ស្បែកជើងមានកង់រំអិល
- ក្តារជិះស្គី
- ស្បែកជើងជិះស្គីរំអិល។

### ការជិះដោយសុវត្ថិភាព

ថ្វីបើកុមាររៀនឆាប់ចេះធាក់កង់ កាច់ចង្កូត និងចាប់ហ្វ្រាំងក៏ដោយក៏ពួកគេមិនបានត្រៀមខ្លួនជិះកង់ជុំវិញនៅជិតផ្លូវចរាចរណ៍ ឬនៅតាមដងផ្លូវទេ។ កូនរបស់អ្នកគួរតែជិះកង់ឱ្យឆ្ងាយពីរថយន្ត និងច្រកផ្លូវឡានរហូតដល់ពួកគេមានអាយុយ៉ាងហោចណាស់១០ឆ្នាំ។

ទីកន្លែងដែលមានសុវត្ថិភាពបំផុតដើម្បីជិះកង់ កង់ក្មេងជិះរុញ ហើយឈរពីលើ និងក្តារជិះស្គី គឺស្ថិតនៅក្នុងបរិវេណតំបន់ហ៊ុមព័ទ្ធដោយរបង។ ការនេះអាចជួយកូនរបស់អ្នកមិនឱ្យជិះ ឬធ្លាក់លើផ្លូវដើរ ឬផ្លូវថ្នល់។ កុមារអាយុក្រោម១៦ឆ្នាំ និងអ្នកជិះអមជាមួយដែលជាមនុស្សធំ អាចជិះលើផ្លូវដើរ លុះត្រាតែមានផ្លាកសញ្ញាហាមជិះកង់បញ្ជាក់ជាក់លាក់។ អ្នកជិះត្រូវប្រុងប្រយ័ត្នជាពិសេស នៅច្រកផ្លូវឡានដែលរថយន្តអាចបើកចូល ឬចេញ។

នៅលើផ្លូវប្រសព្វ អ្នកជិះត្រូវចុះពីលើកង់ ហើយរុញកង់ឆ្លងកាត់ផ្លូវធ្វើជាអ្នកថ្មើរជើង ដោយអនុវត្តតាមវិធី **ឈប់! មើល! ស្តាប់! គិត! (STOP! LOOK! LISTEN! THINK!)**។

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅគេហទំព័រ **safetytown.com.au**

**សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នកដែលរៀននៅថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី៤**

- ត្រូវពាក់មួកសុវត្ថិភាពជានិច្ចនៅពេលអ្នកជិះកង់ ឬជិះស្គី
- ត្រូវជិះកង់ឱ្យឆ្ងាយពីផ្លូវថ្នល់

**សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នកដែលរៀននៅថ្នាក់ទី៥ និងទី៦**

- ត្រូវពាក់មួកសុវត្ថិភាពជានិច្ចនៅពេលអ្នកជិះកង់ ឬជិះស្គី
- ត្រូវជិះកង់ឱ្យឆ្ងាយពីផ្លូវមមាញឹក

Khmer

# សុវត្ថិភាពតាមផ្លូវថ្នល់



## ការណែនាំសម្រាប់អ្នកក្នុងការបើកបរ និងចតរថយន្ត ដោយសុវត្ថិភាពនៅក្បែរសាលា

ថ្ងៃចាប់ផ្តើមចូលរៀន និងចេញពីរៀនគឺជាពេលមមាញឹកដែលមានអ្នកថ្មើរជើង និងរថយន្តជាច្រើននៅក្រៅសាលា។ នោះហើយជាមូលហេតុដែលអ្នកត្រូវប្រុងប្រយ័ត្នបន្ថែម នៅក្នុងតំបន់សាលាកំណត់ល្បឿន៤០គីឡូម៉ែត្រ/ម៉ោង។

- ចតដោយសុវត្ថិភាព និងស្របតាមច្បាប់ បើទោះបីជាត្រូវដើរឆ្ងាយទៅក្លោងទ្វារសាលាក៏ដោយ។ ផ្លាកសញ្ញាចតរថយន្តត្រូវបានគ្រោងរៀបចំដោយផ្តោតលើសុវត្ថិភាពរបស់កុមារ។
- បន្ថយល្បឿនរហូតដល់៤០គីឡូម៉ែត្រ/ម៉ោងនៅក្នុងតំបន់សាលារៀន ហើយត្រូវដឹងអំពីកន្លែងដើរឆ្លងកាត់។
- ត្រូវចត និងបត់ឡានស្របតាមច្បាប់ជានិច្ច នៅជុំវិញសាលារៀន។
- មិនត្រូវចតនៅកន្លែងមានរថយន្តចតឡើយ ដ្បិតអីការនេះធ្វើឱ្យកុមារប្រឈមនឹងគ្រោះថ្នាក់។
- ការបត់ឡានទៅក្រោយរាងជាអក្សរ U (U-turns) និងការបត់ឡានទៅក្រោយតាមរបៀប three-point turns គឺមានគ្រោះថ្នាក់ ។
- មិនត្រូវចតនៅតំបន់រថយន្តក្រុង ឬនៅចំណតរថយន្តក្រុងឡើយ។
- ត្រូវធានាថាកូនរបស់អ្នកប្រើទ្វារសុវត្ថិភាព ( ទ្វាររថយន្តខាងក្រោយនៅចំហៀងផ្លូវដើរ ) ដើម្បីចូល និងចេញពីរថយន្ត។
- នៅកន្លែងដើរឆ្លងកាត់ក្រោមការត្រួតពិនិត្យ ត្រូវមើលទិសដៅរបស់អ្នកត្រួតពិនិត្យការដើរឆ្លងកាត់សាលា។
- ធ្វើគំរូឥរិយាបថដែលមានសុវត្ថិភាព និងមានការគិតគូរដល់កូនរបស់អ្នក – នោះពួកគេនឹងរៀនពីអ្នក។

ចូរចងចាំជានិច្ចបើកផ្លូវឱ្យអ្នកថ្មើរជើង ជាពិសេសនៅពេលចូល និងចេញពីច្រកផ្លូវឡាន។ កុំចតបាំងច្រកផ្លូវចូលសាលារៀន ឬច្រកផ្លូវចូលទៅកន្លែងចតរថយន្តរបស់សាលា។ ជាការល្អដែលត្រូវប្រើកន្លែងដឹកកូនដាក់សាលា និងទៅយកកូនពីសាលាដែលបានកំណត់ឡើងដោយសាលារបស់អ្នក។ ការនេះនឹងជួយរក្សាសុវត្ថិភាពកុមារទាំងអស់ តាមលទ្ធភាពដែលអាចធ្វើទៅបានក្នុងអំឡុងពេលមមាញឹកបំផុតនៃថ្ងៃរៀន។

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅគេហទំព័រ
**safetytown.com.au**

ជីវិតមនុស្សដែលបានបាត់បង់នៅលើផ្លូវថ្នល់រដ្ឋ NSW។
**គោលដៅរបស់យើង គឺគ្មានគ្រោះថ្នាក់ ។**

NSW GOVERNMENT

TOWARDS ZERO

Khmer

# សុវត្ថិភាពតាមផ្លូវថ្នល់




## ការរក្សាសុវត្ថិភាពនៅជុំវិញកន្លែងដើរឆ្លងសាលារៀន

ដើម្បីសុវត្ថិភាពរបស់កូនអ្នក វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធានាថាពួកគេប្រើប្រាស់កន្លែងដើរឆ្លងសាលារៀន។

នៅកន្លែងដើរឆ្លងទាំងអស់ អ្នកត្រូវតែរង់ចាំនៅលើផ្លូវដើរ ហើយថយយ៉ាងហោចណាស់មួយជំហានពីគែមផ្លូវ។

ប្រសិនបើមានអ្នកត្រួតពិនិត្យនៅកន្លែងដើរឆ្លងសាលារៀន ត្រូវនៅរង់ចាំរហូតដល់ពួកគេបានធ្វើសញ្ញាបញ្ឈប់ចរាចរណ៍ ហើយហៅអ្នកឱ្យដើរឆ្លង។




ប្រសិនបើអ្នកកំពុងបើកបរ អ្នកមិនត្រូវបន្តដំណើរឡើយ រហូតទាល់តែអ្នកត្រួតពិនិត្យនៅកន្លែងដើរឆ្លងសាលារៀន ឈប់លើកបង្ហាញផ្លាកសញ្ញា ឬរហូតទាល់តែអ្នកត្រួតពិនិត្យនៅកន្លែងដើរឆ្លងសាលារៀនបញ្ជាក់ថាអ្នកអាចបន្តបើកបាន។

### ផ្លូវដើរឆ្លងសម្រាប់កុមារ

ផ្លូវដើរឆ្លងសម្រាប់កុមារ ជាទូទៅគឺជាផ្លូវដើរឆ្លងក្រៅម៉ោងដែលបើកដំណើរការមុនម៉ោងចូលរៀន និងក្រោយម៉ោងចេញពីរៀន។ ផ្លូវដើរឆ្លងទាំងនេះក៏អាចបើកដំណើរនៅពេលផ្សេងទៀតដែរ ពេលណាកុមារប្រើផ្លូវដើរឆ្លងសម្រាប់ដំណើរកម្សាន្ត ឬក្នុងអំឡុងពេលចេញលេង។ នៅពេលឃើញបង្ហាញទង់ 'Children Crossing' អ្នកត្រូវឈប់នៅខ្សែបន្ទាត់ពណ៌ស ប្រសិនបើអ្នកថ្មើរជើងកំពុងរង់ចាំដើរឆ្លងផ្លូវ។ អ្នកបើកបរត្រូវនៅចាំ រហូតទាល់តែអ្នកថ្មើរជើងដើរឆ្លងអស់។

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅគេហទំព័រ **safetytown.com.au**

Khmer

# សុវត្ថិភាពតាមផ្លូវថ្នល់




## តំបន់សាលាកំណត់ល្បឿន៤០គីឡូម៉ែត្រ/ម៉ោង

តំបន់សាលាកំណត់ល្បឿន៤០គីឡូម៉ែត្រ/ម៉ោង បន្ថយល្បឿនចរាចរណ៍នៅលើដងផ្លូវជុំវិញសាលារៀន។ ការនេះគឺដើម្បីជួយការពារកុមារធ្វើដំណើរនៅតាមដងផ្លូវទៅកាន់សាលា និងមកពីសាលាតាមពេលវេលា និងទីកន្លែងដែលញឹកញាប់មានកុមារធ្វើដំណើរ។ តំបន់សាលាកំណត់ល្បឿន៤០គីឡូម៉ែត្រ/ម៉ោងភាគច្រើន ប្រតិបត្តិការពីម៉ោង៨ព្រឹក ដល់ម៉ោង៩.៣០ព្រឹក និងចាប់ពីម៉ោង២.៣០រសៀល ដល់៤.០០ល្ងាច។ ល្បឿនកំណត់៤០គីឡូម៉ែត្រ/ម៉ោងក្នុងតំបន់សាលា ត្រូវតែគោរពតាមទោះបីជាមើលមិនឃើញសិស្សសាលាក៏ដោយ។

តំបន់សាលាកំណត់ល្បឿន៤០គីឡូម៉ែត្រ/ម៉ោង ប្រតិបត្តិការគ្រប់ថ្ងៃរៀនទាំងអស់ដែលបានជូនដំណឹង រួមទាំងថ្ងៃអភិវឌ្ឍសមត្ថភាពបុគ្គលិក (ថ្ងៃឈប់សម្រាកគ្មានសិស្ស)។ ខណៈពេលដែលសាលារៀនមួយចំនួនអាចប្រតិបត្តិការតាមកាលបរិច្ឆេទ ឆមាសផ្សេងៗគ្នា ការកំណត់ល្បឿនក្នុងតំបន់សាលាត្រូវតែអនុវត្តតាមក្នុងអំឡុងឆមាសសាលារដ្ឋ NSW ដែលបានកំណត់។

អ្នកអាចរកឃើញកាលបរិច្ឆេទឆមាសសាលា នៅតាមគេហទំព័រដូចខាងក្រោម៖

- **roadsafety.transport.nsw.gov.au**
- **educationstandards.nsw.edu.au**
- **education.nsw.gov.au**

ដើម្បីបង្កើនការយល់ដឹងរបស់អ្នកបើកបររថយន្តលើតំបន់សាលាដែលកំណត់ល្បឿន៤០គីឡូម៉ែត្រ/ម៉ោង គំនូសសញ្ញាសម្គាល់ផ្លូវ 'ធ្មេញនាគ' រាងត្រីកោណបង្ហាញថា រថយន្តកំពុងបើកចូលក្នុងតំបន់សាលា។

ការពិន័យជាប្រាក់ និងការបាត់បង់ពិន្ទុពិន័យនឹងត្រូវអនុវត្ត ប្រសិនបើមិនគោរពតាមល្បឿនកំណត់៤០គីឡូម៉ែត្រ/ម៉ោង។ ចំពោះព័ត៌មានបន្ថែមអំពីប្រាក់ពិន័យ និងពិន្ទុពិន័យ សូមចូលមើលវិបសៃ **rms.nsw.gov.au**

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅត្រង់វិបសៃ **safetytown.com.au**

# សុវត្ថិភាពតាមផ្លូវថ្នល់




## ការបើកបរដោយសុវត្ថិភាព នៅជិតរថយន្តក្រុងរបស់សាលារៀន

មានល្បឿនកំណត់៤០គីឡូម៉ែត្រ/ម៉ោងសម្រាប់ចរាចរណ៍ដែលបើកកាត់រថយន្តក្រុងរបស់សាលារៀន ដែលកំពុងដាក់សិស្សចុះពីរថយន្តក្រុង ឬកំពុងដឹកសិស្សឡើងរថយន្តក្រុង។ ការកំណត់ល្បឿននេះគឺសម្រាប់ចរាចរណ៍ទាំងអស់ដែលធ្វើដំណើរតាមទិសដៅ ស្របគ្នានឹងរថយន្តក្រុង ទោះថារថយន្តក្រុងកំពុងចត ឬកំពុងបើកបរក្តី។

ភ្លើងនឹងបើកភ្លឹបភ្លែតៗនៅខាងមុខ និងខាងក្រោយរថយន្តក្រុងដើម្បីរំឭកដល់អ្នកបើកបរទាំងឡាយថាអាចមានកូនក្មេងកំពុងដើរឆ្លងផ្លូវ ឬបម្រុងនឹងដើរឆ្លងផ្លូវ។

រថយន្តក្រុងមិនអាចបញ្ឈប់បានភ្លាមៗទេ ដ្បិតអីវាជារថយន្តធំធុនធ្ងន់។ ដូច្នេះសូមចងចាំថា៖

- បន្ថយល្បឿនទៅ៤០គីឡូម៉ែត្រ/ម៉ោង ពេលណាភ្លើងសញ្ញារថយន្តក្រុងបញ្ចេញពន្លឺភ្លឹបភ្លែតៗ
- បើកផ្លូវឱ្យរថយន្តក្រុង
- ប្រយ័ត្នចំពោះក្មេងដើរឆ្លងកាត់ផ្លូវ
- មិនត្រូវចតនៅក្នុង ឬនៅក្បែរចំណតរថយន្តក្រុង ឬតំបន់រថយន្តក្រុងទេ។

### ចំណតរថយន្តក្រុងរបស់សាលារៀនក្រៅផ្លូវការ

ចំណតរថយន្តក្រុងក្រៅផ្លូវការពុំមានដាក់ផ្លាកសញ្ញាទេ ហើយជាទូទៅគេតែងឃើញមាននៅតាមតំបន់ជនបទ។ ចំណតរថយន្តក្រុងទាំងនេះអាចនៅចំពីមុខផ្ទះ ឬនៅតាមដងផ្លូវដែលអាចធ្វើឱ្យកូនក្មេងពិបាកមើលឃើញ។

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតា នៅគេហទំព័រ **safetytown.com.au**

Khmer

# សុវត្ថិភាពតាមផ្លូវថ្នល់

## ការជួយកុមារឡើង និងចុះពីរថយន្តក្រុងដោយសុវត្ថិភាព

កូនរបស់អ្នកមានគ្រោះថ្នាក់បំផុតក្នុងរយៈពេលប៉ុន្មាននាទីក្រោយចុះពីរថយន្តក្រុង។ ទាំងនេះគឺជាមធ្យោបាយមួយចំនួនដែលអ្នកអាចកាត់បន្ថយគ្រោះថ្នាក់នេះ៖

- ត្រូវទៅយកកូនរបស់អ្នកនៅចំណតរថយន្តក្រុងជានិច្ច។ មិនត្រូវទៅយកកូនរបស់អ្នកនៅម្ខាងផ្លូវ ហើយហៅកូនឱ្យដើរឆ្លងផ្លូវទេ។
- ត្រូវរង់ចាំរហូតទាល់តែរថយន្តក្រុងបើកចេញផុត បន្ទាប់មកជ្រើសរើសកន្លែងសុវត្ថិភាពដើម្បីដើរឆ្លងផ្លូវ។
សូមចងចាំ **ឈប់! មើល! ស្តាប់! គិត!**
- ប្រសិនបើអ្នកមិនអាចទៅយកកូនរបស់អ្នកទេ ត្រូវរៀបចំមនុស្សធំទង់ម្នាក់ទៀតដែលអាចទុកចិត្តបាន ដើម្បីទៅយកកូនជំនួសអ្នក។
- ត្រូវរង់ចាំនៅចំណតរថយន្តក្រុង ហើយឈរថយក្រោយយ៉ាងហោចណាស់មួយជំហានពីគែមផ្លូវ។
- ត្រូវរង់ចាំរហូតទាល់តែរថយន្តក្រុងបើកចេញផុត បន្ទាប់មកប្រើកន្លែងសុវត្ថិភាពដើម្បីដើរឆ្លងផ្លូវ។
- ត្រូវពាក់ខ្សែក្រវាត់សុវត្ថិភាព ប្រសិនបើរថយន្តក្រុងមានខ្សែក្រវាត់សុវត្ថិភាព។

ត្រូវបង្ហាញពីគំរូឥរិយាបថអ្នកថ្មើរជើងដែលមានសុវត្ថិភាព។ កុមាររៀនពីទម្លាប់អ្នកប្រើប្រាស់ផ្លូវដោយសុវត្ថិភាពពីអ្នក ហើយនឹងបន្តទម្លាប់នេះនៅពេលក្រោយមក នៅពេលពួកគេមានអាយុគ្រប់គ្រាន់ក្នុងការធ្វើដំណើរតែម្នាក់ឯង។

លុះត្រាតែកូនរបស់អ្នកមានអាយុយ៉ាងហោចណាស់ប្រាំបីឆ្នាំ ត្រូវកាន់ដៃកូនរបស់ពួកគេនៅពេលដើរលើផ្លូវដើរ នៅកន្លែងចតរថយន្ត និងនៅពេលដើរឆ្លងផ្លូវ។ រហូតទាល់តែកូនរបស់អ្នកមានអាយុយ៉ាងហោចណាស់១០ឆ្នាំ ត្រូវកាន់ដៃវានៅពេលដើរឆ្លងផ្លូវ។

**ឈប់! (STOP!)**
ថយមួយជំហានពីចិញ្ចើមផ្លូវ

**មើល! (LOOK!)**
ផ្លូវទាំងសងខាងជាបន្តឥតឈប់

**ស្តាប់! (LISTEN!)**
រកសំឡេងចរាចរណ៍ដែលបើកជិតមកដល់

**គិត! (THINK!)**
ថាតើវាមានសុវត្ថិភាពក្នុងការដើរឆ្លងផ្លូវឬទេ ហើយបន្តឆែកមើលផ្លូវ រហូតទាល់តែបានដើរឆ្លងផុតដោយសុវត្ថិភាព

### សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នកដែលរៀននៅមត្តេយ្យសាលា ទៅថ្នាក់ទី២

- កាន់ដៃមនុស្សធំពេលណា៖
  - អ្នកដើរឆ្លងផ្លូវ
  - អ្នកស្ថិតនៅលើផ្លូវដើរ
  - អ្នកស្ថិតនៅកន្លែងចតរថយន្ត

### សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នកដែលរៀននៅថ្នាក់ទី៣ និងទី៤

- កាន់ដៃមនុស្សធំពេលណាអ្នកដើរឆ្លងផ្លូវ
- ប្រើកន្លែងសុវត្ថិភាពដើម្បីដើរឆ្លងផ្លូវ

### សារសម្រាប់ចែករំលែកជាមួយកូនៗរបស់អ្នកដែលរៀននៅថ្នាក់ទី៥ និងទី៦

- **ឈប់! មើល! ស្តាប់! គិត!** រាល់ពេលអ្នកដើរឆ្លងផ្លូវ ហើយបន្តឆែកមើលផ្លូវ រហូតទាល់តែបានដើរឆ្លងផុតដោយសុវត្ថិភាព

### ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី៦

- ត្រូវរង់ចាំរហូតទាល់តែរថយន្តក្រុងបើកចេញផុត រួចហើយប្រើកន្លែងសុវត្ថិភាពដើម្បីដើរឆ្លងផ្លូវ

ចំពោះព័ត៌មានបន្ថែម ស្តីពីការរក្សាសុវត្ថិភាពកូនៗរបស់យើងនៅជុំវិញសាលារៀន សូមចូលមើលផ្នែកសម្រាប់មាតាបិតានៅគេហទំព័រ **safetytown.com.au**